សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association

# សេចក្ដីថ្លែងការណ៍
# ខេមបូចាទទូចឱ្យមានការគោរពសេរីភាពនិងសិទ្ធិទទួលព័ត៌មានរបស់អ្នកសារព័ត៌មានអំពីវ៉ាក់សាំងការពារជំងឺកូវីដ-១៩

ភ្នំពេញ ថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ - សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ហៅកាត់ថា ខេមបូចា) ទទូចដល់រាជរដ្ឋាភិបាលឱ្យធានាសេរីភាព និងសិទ្ធិទទួលព័ត៌មានរបស់អ្នកសារព័ត៌មានទាំងអស់ដោយមិនរើសអើង ដើម្បីឱ្យពួកគេអាចស្វែងរក ទទួល និងផ្សព្វផ្សាយព័ត៌មានស្ដីពីវ៉ាក់សាំងការពារជំងឺកូវីដ-១៩ដោយសេរី និងស្មើភាពគ្នា។

នៅព្រឹកថ្ងៃទី ០៤ ខែមីនានេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងភរិយា ព្រមទាំងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលជាច្រើនរូបផ្សេងទៀត បានអញ្ជើញចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ផលិតដោយក្រុមហ៊ុនអាស្ត្រាហ្សេនីកា (Astra zeneca) នៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ ហើយបានធ្វើសន្និសីទសារព័ត៌មានពាក់ព័ន្ធនឹងវ៉ាក់សាំងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅកម្ពុជា។

នៅក្នុងព្រឹត្តិការណ៍នេះ មានអ្នកសារព័ត៌មានមកពីស្ថាប័នមួយចំនួនដូចជា វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) ទីភ្នាក់ងារព័ត៌មានរ៉យទ័រ (Reuters) ទីភ្នាក់ព័ត៌មានអេភី (AP) វីអូឌី (VOD) ខេមបូណូមីស (Cambonomist) ថ្មីថ្មី (Thmey Thmey) និងខេមបូចា ញូស៍ (CamboJA News) ។ល។ ត្រូវបានអាជ្ញាធរ និងមន្ត្រីពិធីការហាមឃាត់មិនឱ្យចូលយកព័ត៌មាននិងថតរូបនៅក្នុងព្រឹត្តិការណ៍នេះទេ។ ផ្ទុយទៅវិញ មានតែអ្នកសារព័ត៌មានមកពីស្ថាប័នសារព័ត៌មានដែលស្និតនឹងរដ្ឋាភិបាលដូចជាសារព័ត៌មាន Fresh News ទូរទស្សន៍ជាតិកម្ពុជា (ទទក) ទូរទស្សន៍បាយ័ន និងទូរទស្សន៍ CNC តែប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យចូលយកព័ត៌មាន។ ការណ៍នេះបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានព័ត៌មានរបស់អ្នកសារព័ត៌មានដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់រដ្ឋធម្មនុញ្ញ និង មាត្រា៥នៃច្បាប់ស្ដីពីរបបសារព័ត៌មាន ព្រមទាំងបានបង្ហាញអំពីវិសមភាពរវាងអ្នកសារព័ត៌មានមកពីស្ថាប័នសារព័ត៌មានផ្សេងៗគ្នា។

នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) លោក ណុប វី មានប្រសាសន៍ថា៖ « ស្ថាប័នសារព័ត៌មាននីមួយៗកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានដល់អ្នកអាន អ្នកស្តាប់ និងអ្នកទស្សនាផ្សេងៗពីគ្នា ជាពិសេសក្នុងស្ថានភាពដែលកម្ពុជាកំពុងទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ-១៩។ ការហាមឃាត់អ្នកសារព័ត៌មានពីការទទួលបានព័ត៌មានដោយសេរី គឺអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋដែលជាអ្នកអាន អ្នកស្តាប់ និងអ្នកទស្សនា »។

ខេមបូចាដែលមានសមាជិក សមាជិកា និងក្រុមប្រឹក្សាភិបាលជាអ្នកសារព័ត៌មានជាង ១០០នាក់ កំពុងចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលដើម្បីលើកកម្ពស់សេរីភាពនិងសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកសារព័ត៌មាន៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net